CHIP MONG BANK

# ពាក្យស្នើសុំផ្ទេរប្រាក់ក្រៅប្រទេស

## OUTWARD REMITTANCE APPLICATION

Form No.: CMCB- OTT001

## ព័ត៌មានអ្នកស្នើសុំផ្ទេរ APPLICANT INFORMATION

| | | |
|---|---|---|
| ឈ្មោះអ្នកស្នើសុំ Applicant's name: | | សាខា Branch: |
| លេខគណនី Account No.: | | ទូរស័ព្ទ Tel: |
| អាសយដ្ឋាន Address: | | |

## ព័ត៌មានអ្នកទទួលផល BENEFICIARY INFORMATION

| | | |
|---|---|---|
| ឈ្មោះអ្នកទទួលផល Beneficiary's name: | | |
| អាសយដ្ឋាន Address: | | |
| លេខគណនី Account No. / IBAN: | | ទូរស័ព្ទ Tel: |
| ឈ្មោះធនាគារ Bank name: | | |
| អាសយដ្ឋានធនាគារ Bank Address: | | |
| លេខកូដ SWIFT/BIC/ABA No: | | |

| | |
|---|---|
| ទឹកប្រាក់សុំផ្ទេរ Wire Amount: | |
| ជាអក្សរ in Words: | |
| គោលបំណងផ្ទេរប្រាក់ Purpose of Transfer: | ☐ ទូទាត់ទំនិញ Goods Payment (Invoice No: ________ )<br>☐ ផ្ទេរជូនសាច់ញាតិ/គ្រួសារ Family Support ☐ ផ្ទេរទូទាត់កម្ចី Loan Payment<br>☐ ផ្សេងៗ Other (សូមបញ្ជាក់) ________ |
| ព័ត៌មានបន្ថែម Description if any: | |
| ទំនាក់ទំនងហិរញ្ញវត្ថុ Financial Relation | ☐ Yes មានទំនាក់ទំនង ☐ No គ្មានទំនាក់ទំនង ☐ I don't know មិនដឹងពីទំនាក់ទំនង |
| ការទូទាត់កម្រៃធនាគារ Bank Charges: | ☐ BEN កាត់ក្នុងទឹកប្រាក់សុំផ្ទេរ Deducted in above wire amount<br>☐ SHA កាត់ដោយឡែកពីចំនួនសុំផ្ទេរ Deducted separately from above account<br>☐ OUR កាត់ ទាំងសោហ៊ុយធនាគារក្រៅប្រទេស Cover all overseas bank charges |

ខ្ញុំ/យើងខ្ញុំបានអាន និងឯកភាពលក្ខខណ្ឌផ្ទេរប្រាក់នៅទំព័រខាងក្រោយ I/We have read and agreed the terms and conditions stipulated on the backside of this application.

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ Signature & name

កាលបរិច្ឆេទ Date:........../........../...................

**សំរាប់តែធនាគារ FOR BANK USE ONLY**

| | |
|---|---|
| WIRE AMOUNT: | |
| BANK TT FEE: | |
| SWIFT COST: | |
| OVERSEAS FEE: | |
| **TOTAL AMOUNT:** | |
| មន្ត្រីធនាគារ TELLER | អនុម័តដោយ AUTHORIZED BY |

**លក្ខខណ្ឌអនុវត្តសំរាប់ការផ្ទេរប្រាក់ក្រៅប្រទេស**

សូមលោកអ្នកអានលក្ខខណ្ឌខាងក្រោមអោយបានយល់ច្បាស់មុននឹងដាក់ពាក្យសុំផ្ទេរប្រាក់។ នៅពេលបានទទួលពាក្យស្នើសុំនេះពីលោកអ្នកមានន័យថាលោកអ្នកឯកភាព និងប្រតិបត្តិតាមលក្ខខណ្ឌខាងក្រោម។

**១-ការទទួលខុសត្រូវរបស់អតិថិជន**

ក)លោកអ្នកអះអាង និងបញ្ជាក់ច្បាស់ថា ព័ត៌មាននៅក្នុងពាក្យសុំពិតជាត្រឹមត្រូវ និងគ្រប់គ្រាន់។ ការទទួលពាក្យស្នើសុំផ្ទេរប្រាក់របស់លោកអ្នកគឺជាឆន្ទានុសិទ្ធិរបស់ធនាគារ។

ខ)លោកអ្នកឯកភាពជាមួយកម្រៃសេវាធនាគារ។

គ)លោកអ្នកទទួលខុសត្រូវដោយខ្លួនឯងលើភាពត្រឹមត្រូវ និងសុវត្ថិភាពនៃការស្នើសុំផ្ទេរប្រាក់តាមសេវាអ៊ីនធឺណិតធនាគារ។

ឃ)លោកអ្នកត្រូវគោរពច្បាប់ពាក់ព័ន្ធនឹងការផ្ទេរប្រាក់ និងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។

**២-ការផ្ទេរប្រាក់**

ក)ករណីការផ្ទេរប្រាក់ជារូបិយប័ណ្ណផ្សេងពីរូបិយប័ណ្ណក្នុងគណនីលោកអ្នក នោះអត្រាប្តូរប្រាក់ប្រចាំថ្ងៃនៃថ្ងៃធ្វើប្រតិបត្តិការរបស់ធនាគារនឹងត្រូវបានប្រើប្រាស់។

ខ)អត្រាប្តូរប្រាក់នៅលើសេវាធនាគារតាមអ៊ីនធឺណិតគឺគ្រាន់តែជាអត្រាយោង។ អត្រាប្តូរប្រាក់ដែលត្រូវអនុវត្តគឺអត្រាប្តូរប្រាក់ប្រចាំថ្ងៃនៃថ្ងៃធ្វើប្រតិបត្តិការរបស់ធនាគារ។

**៣-កម្រៃសេវាធនាគារ**

សូមមើលតារាងកម្រៃសេវា និងការចំណាយផ្សេងៗចុងក្រោយបំផុតរបស់ធនាគារសំរាប់ការផ្ទេរប្រាក់ និងសេវាផ្សេងៗ។ ដោយធនាគារដៃគូក្រៅប្រទេសគិតកម្រៃសេវាដែរនោះ អ្នកទទួលផលអាចមិនទទួលបានចំនួនទឹកប្រាក់ជាក់ស្តែងដូចចំនួនដែលបានស្នើសុំផ្ទេរលើកលែងតែលោកអ្នកបង់កម្រៃសេវាសំរាប់ធនាគារដៃគូ។

**៤. ពេលវេលាកំណត់សំរាប់ប្រតិបត្តិការ**

ប្រសិនបើចង់ឲ្យការផ្ទេរប្រាក់របស់លោកអ្នកធ្វើប្រតិបត្តិការក្នុងថ្ងៃតែមួយ លោកអ្នកត្រូវផ្តល់ជូនធនាគារនូវពាក្យសុំផ្ទេរប្រាក់ក្នុងអំឡុងម៉ោងធ្វើការរបស់ធនាគារតាមសាខាណាមួយរបស់ធនាគារ។ បើមិនដូច្នោះទេ ការផ្ទេរប្រាក់របស់លោកអ្នកនឹងត្រូវដំណើរការនៅថ្ងៃធ្វើការបន្ទាប់។ ពេលវេលាកំណត់នេះត្រូវអនុវត្តផងដែរសំរាប់ការស្នើសុំផ្ទេរប្រាក់តាមសេវាអ៊ីនធឺណិតធនាគារ។

**៥. ការពន្យាពេលប្រតិបត្តិការ**

ការផ្ទេរប្រាក់របស់លោកអ្នកអាចត្រូវបានពន្យាពេល ឬក្លាយជាបាត់បង់ ប្រសិនបើលោកអ្នកផ្តល់នូវសំណើសុំផ្ទេរប្រាក់ដែលមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់។ ជាធម្មតា ធនាគារនឹងសាកសួរព័ត៌មានបន្ថែមពីលោកអ្នក។ ប្រសិនបើលោកអ្នកមិនអាចផ្តល់ព័ត៌មានលំអិតជូនធនាគារ នោះប្រាក់របស់លោកអ្នកនឹងត្រូវបានផ្ញើត្រឡប់មកធនាគារយើងខ្ញុំ បន្ទាប់មកនឹងផ្តល់ជូនលោកអ្នកវិញ។

**៦. ការផ្ញើត្រឡប់នូវការផ្ទេរប្រាក់**

ប្រសិនបើការផ្ទេរប្រាក់ត្រូវបានបដិសេធមិនទទួលដោយអ្នកទទួលផល ឬបញ្ជូនមកវិញដោយធនាគារដៃគូ ធនាគារយើងខ្ញុំនឹងជូនដំណឹងទៅលោកអ្នក និងផ្ទេរប្រាក់នៅសល់ជូនលោកអ្នកវិញ(ចំនួននេះដកចេញនូវសោហ៊ុយ និងចំណាយផ្សេងៗ ដែលត្រូវបង់ជូនធនាគារយើងខ្ញុំ និងធនាគារដៃគូ)។

**៧. ការលុបចោលប្រតិបត្តិការ**

លោកអ្នកអាចស្នើសុំលុបចោល ឬកែតម្រូវនូវសំណើសុំផ្ទេរប្រាក់ ប្រសិនបើធនាគារយល់ព្រមតាមសំណើនោះ។ ប្រសិនបើធនាគារយល់ព្រម លោកអ្នកត្រូវបង់សោហ៊ុយសំរាប់ការលុបចោលនោះ។ សំរាប់ព័ត៌មានលំអិតសូមមើល តារាងតម្លៃចុងក្រោយបំផុតរបស់ធនាគារសំរាប់ការផ្ទេរប្រាក់ និងសេវាផ្សេងៗ។ លោកអ្នកយល់ព្រមទទួលខុសត្រូវសំរាប់ការបាត់បង់នានា សោហ៊ុយ ឬចំណាយផ្សេងៗពាក់ព័ន្ធនឹងការស្នើសុំលុបចោលរបស់លោកអ្នក។

**៨. ព័ត៌មានអតិថិជន និងការរក្សាការសម្ងាត់**

ធនាគារអាចប្រមូល ឬចែករំលែកព័ត៌មានអាជីវកម្មផ្ទាល់ខ្លួនរបស់លោកអ្នក ទៅភាគីដែលពាក់ព័ន្ធរួមមាន សាខាធនាគារ ការិយាល័យឥណទានកម្ពុជា ធនាគារជាតិនៃកម្ពុជា  អាជ្ញាកណ្តាល ឬបុគ្គលដែលលោកអ្នកធ្វើប្រតិបត្តិការជាមួយ ស្ថាប័នហិរញ្ញវត្ថុ ធនាគារដៃគូ រដ្ឋាភិបាល ឬអាជ្ញាធរអាណាព្យាបាល ឬភ្នាក់ងារអនុវត្តច្បាប់ដែលមានសមត្ថកិច្ច ទីប្រឹក្សាប្រកបដោយវិជ្ជាជីវៈរបស់ធនាគាររួមមាន មេធាវី សវនករ ទីប្រឹក្សាបច្ចេកទេស ឬទៅអ្នកតំណាងស្របច្បាប់របស់លោកអ្នក។

**៩. ការកែប្រែគោលការណ៍ និងលក្ខខណ្ឌ**

ធនាគាររក្សាសិទ្ធិក្នុងការកែប្រែគោលការណ៍ និងលក្ខខណ្ឌនេះ តាមការចាំបាច់។ ធនាគារនឹងជូនដំណឹងលោកអ្នកតាមគេហទំព័ររបស់ធនាគារ។ ប្រសិនបើលោកអ្នកមិនពេញចិត្តចំពោះការផ្លាស់ប្តូរនេះ លោកអ្នកអាចជ្រើសរើសក្នុងការបិទគណនីរបស់លោកអ្នកដែលមាននៅធនាគារយោងតាមគោលការណ៍ និងលក្ខខណ្ឌរបស់ធនាគារ។

**១០. ការទទួលខុសត្រូវ**

ស្ថិតក្រោមវិសាលភាពដែលអនុញ្ញាតដោយច្បាប់ ធនាគារនឹងមិនទទួលខុសត្រូវសំរាប់ការបាត់បង់ នានា ដែលបណ្តាលមកពីៈ ការស្នើសុំផ្ទេរប្រាក់របស់លោកអ្នកមិនច្បាស់លាស់គ្រប់គ្រាន់ ការខកខានក្នុងការផ្តល់ព័ត៌មានត្រឹមត្រូវ ប្រព័ន្ធមិនដំណើរការ ឬជំលោះនៅក្នុងឧស្សាហកម្ម សកម្មភាពទាំងឡាយណាដែលតម្រូវដោយរដ្ឋាភិបាល ឬអាជ្ញាធរពាក់ព័ន្ធ ច្បាប់ បទបញ្ជា ឬសេចក្តីសំរេចពីតុលាការ ឬក៏អ្វីផ្សេងទៀតដែលមិនមាន ឬកំណត់នៅក្នុងគោលការណ៍ និងលក្ខខណ្ឌនេះ។

**១១. សំណងនៃការខូចខាត**

ស្ថិតក្រោមវិសាលភាពដែលអនុញ្ញាតដោយច្បាប់ លោកអ្នកយល់ព្រមសងនូវរាល់ការខូចខាតដោយមិនកំណត់ដល់ធនាគារចំពោះការអះអាង បណ្តឹង ការទាមទារ ការបាត់បង់ ការខូចខាត សោហ៊ុយ ការចំណាយផ្សេងៗ ឬការទទួលខុសត្រូវបានកើតឡើង ឬគំរាមកំហែងចំពោះធនាគារ ដែលជាលទ្ធផលដោយផ្ទាល់ ឬមិនផ្ទាល់ ឬពាក់ព័ន្ធជាមួយនឹងការផ្ទេរប្រាក់នេះ ប្រសិនបើធនាគារប្រតិបត្តិ ឬខកខានប្រតិបត្តិនូវការបញ្ជារបស់លោកអ្នក លើកលែងតែការទាំងនោះកើតឡើងបណ្តាលមកពី ការធ្វេសប្រហែស ការបន្លំ ឬចេតនាមិនអនុវត្តរបស់ធនាគារ។

**១២. លក្ខខណ្ឌតម្រូវសំរាប់ការប្រឆាំងការសំអាតប្រាក់**

ធនាគារមានកាតព្វកិច្ចអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងបទបញ្ជាពាក់ព័ន្ធផ្សេងៗទៀត។ លោកអ្នកមិនត្រូវធ្វើដោយចេតនាឲ្យធនាគារមិនគោរពតាមច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មទេ។ ធនាគារនឹងធ្វើការពន្យាពេល បង្អាក ឬបដិសេធក្នុងការធ្វើប្រតិបត្តិការ ឬពាក្យស្នើសុំផ្ទេរប្រាក់របស់លោកអ្នកៈ

ក) ពេលដែលធនាគារមានហេតុផលគ្រប់គ្រាន់ដែលជឿជាក់ថា ប្រតិបត្តិការនឹងមិនអនុលោមតាមច្បាប់ ឬបទបញ្ញត្តិពាក់ពាន់រួមបញ្ចូលទាំងច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ព្រះរាជាណាចក្រកម្ពុជា ឬ

ខ) ពេលដែលធនាគារសង្ស័យថា ប្រតិបត្តិការនោះ ពាក់ព័ន្ធនឹងបុគ្គលនានា ( រូបវ័ន្តបុគ្គល ក្រុមហ៊ុន ឬរដ្ឋាភិបាល) ដែលត្រូវបានដាក់ទណ្ឌកម្ម ឬពាក់ព័ន្ធដោយផ្ទាល់ ឬមិនផ្ទាល់ជាមួយបុគ្គលត្រូវបានដាក់ទណ្ឌកម្មស្ថិតក្រោមទណ្ឌកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មដោយប្រទេសនានា ឬ

គ) ពេលដែលធនាគារសង្ស័យថា ប្រាក់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការផ្ទេរនេះ អាចនឹងត្រូវបានប្រើប្រាស់ដោយផ្ទាល់ ឬមិនផ្ទាល់សំរាប់គោលបំណងប្រព្រឹត្តបទល្មើស ឬសកម្មភាពខុសច្បាប់។ប្រសិនបើប្រតិបត្តិការត្រូវបានពន្យាពេល បង្អាក ឬបដិសេធដោយសារហេតុផលខាងលើ ធនាគារនឹងមិនទទួលខុសត្រូវ   ចំពោះលោកអ្នកទេ ហើយលោកអ្នកត្រូវសងធនាគារនូវរាល់ការខូចខាត និងការបាត់បង់ទាំងអស់ដែលបានកើតឡើងដោយលោកអ្នក ឬបុគ្គលផ្សេងទៀតចំពោះការពន្យាពេល ការបង្អាក និងការបដិសេធសំរាប់ប្រតិបត្តិការ ឬពាក្យស្នើសុំនោះ។

**TERMS AND CONDITIONS FOR OUTWARD REMITTANCE**

It is important that you read these Terms and Conditions carefully and understand them fully.
Please let us know if you have any questions.

**1. Customer's responsibility**

a) You confirm that all information provided in this application is true and correct. Acceptance of your application for outward remittances will be subject to the Bank's discretion.

b) You have agreed with the Bank's fees & charge.

c) You may request for a fund transfer via our Internet Banking. However, it is your sole responsibility to ensure the accuracy of the information and the security of your payment order.

d) You are fully responsible for complying with Cambodia and related laws on fund transfer.

**2. Fund Transfer**

a) In case the fund transfer is in a foreign currency different from your account currency, our daily foreign exchange rate will be applied. The selling rate is effective at the time the transaction is successfully completed in our banking system.

b) The exchange rate displayed on the Internet Banking is only an indicative rate for your reference. The effective exchange rate will be defined at the time we have completed your transaction in our banking system.

**3. Bank fees and charges**

Please refer to our latest "Money transfer and other services" leaflet for detail pricing and fee charges. Depending on the fee arrangement with correspondent financial institutions that assist the Bank to process the payment, the amount of payment received by the beneficiary may not necessarily be the same as requested.

**4. Cut-off Time**

If you would like your payment instructions to be processed on the same day, you must provide us with your payment instructions during the working hours on any Business Day at any branch of the Bank. Otherwise, your payment will be processed on the next Business Day. This cut-off time is applicable for any payment instructions through Internet Banking as well.

**5. Transaction Delay**

There is a risk that payment may be delayed or become lost if incomplete or inaccurate payment instructions are provided. Further instructions would normally be sought from you by the Bank. If you are unable to instruct the Bank with further contact details of the beneficiary, the funds will be returned to the Bank so that they can be refunded to you.

**6. Return of Payments**

The Bank will contact you and seek further instructions if required by our correspondent bank. You may instruct the Bank to either amend your payment instructions by providing the correct or additional information in order to proceed with the payment, or instruct the Bank to request a refund from the correspondent bank or the paying bank. If fund refused by your beneficiary/payee or returned by our correspondent bank without any Reason, the Bank will notify you and refund you with the telegraphic transfer amount (less any associated fees and costs charged by our Bank and the correspondent bank.

**7. Transaction Cancellation**

You may only cancel or amend a telegraphic transfer if the Bank agrees to do so at its absolute discretion.  If the Bank agrees to such cancellation, a cancellation fee is charged. Please refer to our latest Money Transfer and Other services for detail information. You agree to be responsible for any loss or costs or expenses associated with your requested cancellation.

**8. Customer Information and Privacy**

We may collect and share your personal/business information to the following third parties: our related branches; Credit Bureau of Cambodia, the National Bank of Cambodia, referees or persons with whom you transact; other financial institutions; our correspondent banks; to government or regulatory bodies or to competent law enforcement agencies; to our professional advisers including lawyers and auditors, consultants; to your duly authorized representatives.

**9. Changing of Terms and Conditions**

We may from time to time change any of these Terms and Conditions. We will notify you via our website. If you are not satisfied with any changes, you may choose to close your account(s) held with the Bank in accordance with Terms and Conditions.

**10. Liabilities**

To the extent permitted by law, we will not be liable to you for any loss due to: any instructions given by you not being sufficiently clear; any failure by you to provide correct information; any systems failure or industrial dispute; any action required by the government or related; law or regulation or court order; or anything specifically excluded or limited elsewhere in these terms and conditions.

**11. Indemnity**

To the extent permitted by law, you agree to indemnify us against any claim, action, demand, loss, damage, cost, expense, or liability incurred by or threatened against us as a direct or indirect result of or in connection with this fund transfer including but without limitation if we act on or fail to act on any instruction by you except to the extent caused by our gross negligent, fraud or willful misconduct.

**12. Anti-Money Laundering Requirements**

We are subject to the Anti-Money Laundering and Counter-Terrorism Financing Law (AML/CTF Law), and related laws and regulations. You must not knowingly put us in breach of any AML/CTF Laws.  We may delay, block or refuse to process any transaction or application:

a) where we have reasonable grounds to believe that allowing the transaction to occur may breach any laws or regulations in any country, including the AML/CTF Laws in Cambodia; or

b) where we suspect that a transaction involves any person (natural, corporate or governmental) that is sanctioned or connected, directly or indirectly, to any person that is sanctioned under economic and trade sanctions imposed by or any other country; or

c) where we suspect that the funds involved in the transaction may directly or indirectly be applied for the purposes of crime or unlawful conduct.If any transaction is delayed, blocked or refused for any of the above reasons, we are not liable to you for, and you indemnify us against, any and all loss i ncurred by you or any other person arising out of such delay, block or refusal of a transaction or application.